ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

លេខ : ០៤២ បទ.សដណ

# សេចក្តីជូនដំណឹង
## ស្តីពី
## វិធានការការពារការវាយប្រហារតាមប្រព័ន្ធតេឡេក្រាម (Telegram) ក្រោមទម្រង់ជាការក្លែងបន្លំឈ្មោះថ្នាក់ដឹកនាំនៃរាជរដ្ឋាភិបាល ឬឈ្មោះបុគ្គលដទៃ

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ សូមជម្រាបជូនដំណឹងដល់សាធារណជនទាំងអស់ មេត្តាជ្រាបថា ការវាយប្រហារតាមប្រព័ន្ធតេឡេក្រាម (Telegram) បាននឹងកំពុងកើតមានឡើងគួរឱ្យកត់សម្គាល់។ ឧក្រិដ្ឋជន (Hacker) បានធ្វើការវាយប្រហារក្រោមទម្រង់ជាការក្លែងបន្លំឈ្មោះថ្នាក់ដឹកនាំក្នុងជួររាជរដ្ឋាភិបាល ឬឈ្មោះបុគ្គលដទៃទៀត ដើម្បីបញ្ជូនមេរោគតាមសារក្នុងកម្មវិធីតេឡេក្រាម សម្រាប់បោកបញ្ឆោតអ្នកប្រើប្រាស់ ( ជនរងគ្រោះ ) ដែលគេបានកំណត់មុខសញ្ញា។ ក្នុងករណី អ្នកប្រើប្រាស់ចុចបើកឯកសារ **ឬកម្មវិធីដែលមានផ្ទុកមេរោគ** ឧក្រិដ្ឋជនអាចចូលទៅគ្រប់គ្រងកុំព្យូទ័រឬទូរសព្ទរបស់អ្នកប្រើប្រាស់ពីចម្ងាយដោយជោគជ័យ ហើយផ្តល់លទ្ធភាពឱ្យឧក្រិដ្ឋជនលួចយកទិន្នន័យនានា ដូចជា ឯកសារ លេខកូដសម្ងាត់ ( Password/ Passcode ) សម្រាប់កម្មវិធីផ្សេងៗ ព្រមទាំងបញ្ជាម៉ាស៊ីនថតរូប (Camera) និងឧបករណ៍ថតសំឡេងផងដែរ ហើយអាចបន្តលួចព័ត៌មាននៅក្នុងកុំព្យូទ័រឬទូរសព្ទ និងប្រើប្រាស់អត្តសញ្ញាណជនរងគ្រោះទៅបោកបញ្ឆោតអ្នកដទៃទៀត។

ដូចនេះ ដើម្បីជៀសវាងការធ្លាក់ទៅក្នុងអន្ទាក់បោកប្រាស់របស់អ្នកវាយប្រហារ អ្នកប្រើប្រាស់តេឡេក្រាមគួរតែផ្ទៀងផ្ទាត់និងត្រួតពិនិត្យគណនីរបស់បុគ្គលដែលបានផ្ញើសារមក ឱ្យបានច្បាស់លាស់។ ជាពិសេស ចំពោះសារណាដែលផ្ញើមកជាលើកដំបូង ទោះបីជាមានរូបភាពនិងឈ្មោះរបស់ថ្នាក់ដឹកនាំក្នុងជួររាជរដ្ឋាភិបាល ឬអ្នកស្គាល់ក៏ដោយ ម្ចាស់គណនីគួរធ្វើការពិនិត្យមើលព័ត៌មានរបស់អ្នកផ្ញើដូចជា លេខទូរសព្ទនិងឈ្មោះ មុននឹងចុចបើកឯកសារនិងកម្មវិធីណាមួយ ឬឆ្លើយតបសារវិញ។ ក្នុងករណីសង្ស័យ អ្នកប្រើប្រាស់គួរតែទូរសព្ទទៅសាកសួរម្ចាស់គណនីដោយផ្ទាល់តែម្តង។ ក្រោយពេលបានដឹងថា ម្ចាស់គណនីមិនមែនជាម្ចាស់គណនីពិតប្រាកដ អ្នកប្រើប្រាស់អាចបិទ (Block) ការទទួលសារពីគណនីនោះ តាមរយៈការជ្រើសរើសយកពាក្យជាភាសាអង់គ្លេស ដែលមានអក្សរពណ៌ក្រហមថា "Block User"។

សម្រាប់ព័ត៌មានបច្ចេកទេសពាក់ព័ន្ធទៅនឹងបញ្ហានេះ អ្នកប្រើប្រាស់អាចស្វែងយល់បន្ថែម ក្នុងគេហទំព័ររបស់ "ការិយាល័យឆ្លើយតបបញ្ហាបន្ទាន់នៃកុំព្យូទ័រ (CamCERT)" នាយកដ្ឋានសន្តិសុខបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន នៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ដែលមានអាសយដ្ឋាន www.camcert.gov.kh ឬរាយការណ៍អំពីករណីនេះតាមរយៈអ៊ីមែល incident@camcert.gov.kh ឬទូរសព្ទលេខ ០២៣ ៧២២ ៣៩១ / ០១៦ ៩៥១ ៦៧៨។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមសាធារណជនទាំងអស់មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃអង្គារ ១កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២០

អាសយដ្ឋាន : អគារលេខ ១៣ មហាវិថីព្រះមុនីវង្ស
សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
គេហទំព័រ : www.mptc.gov.kh
ទូរសព្ទ : (៨៥៥) ២៣ ៧២៤ ៨១០
ទូរសារ : (៨៥៥) ២៣ ៧២៤ ០៦៥
អ៊ីមែល : info@mptc.gov.kh